## Expressing thanks 2




វិបុល៖ កញ្ញា កំពុងធ្វើអីហ្នឹង?
កញ្ញា៖ អូ វិបុល ខ្ញុំកំពុងរកចង់ព្យួររូបថតមួយនេះ។ តែខ្ញុំអត់សូវចេះប្រើញញួរទេ។
វិបុល៖ ចាំខ្ញុំជួយអីចឹង! ចង់ព្យួរដាក់ត្រង់ណា?
កញ្ញា៖ ខ្ញុំចង់ដាក់វាត្រង់នេះ។
វិបុល៖ អូខេ។ ជួយទ្រពីក្រោមបន្តិចមកអីចឹង។
កញ្ញា៖ ចាស។ ប្រយ័ត្នវ៉ៃត្រូវដៃខ្លួនឯងណា។
ប៉ុកៗ (សំឡេងញញួរ)
វិបុល៖ រួចហើយ! ប៉ុណ្ណឹងបានអត់?
កញ្ញា៖ ប៉ុណ្ណឹងបាន / ល្មមហើយ វិបុល។ អរគុណច្រើន!
វិបុល៖ អូខេ / មិនអីទេ។

| | |
|---|---|
| វិបុល / កញ្ញា | Cambodian names (male / female) |
| រកចង់ | to be about to |
| ព្យួររូបថត | to hang a picture |
| ញញួរ | hammer |
| ចាំខ្ញុំជួយអីចឹង! | Let me help you then! |
| ទ្រពីក្រោម | to support from below, to hold from below |
| វ៉ៃ | spoken form of វាយ = to hit |
| ប៉ុណ្ណឹងបានអត់? | Is it good enough? / Like this? |

## Cultural notes

នៅប្រទេសកម្ពុជាក៏ដូចជានៅប្រទេសផ្សេងៗដែរ គឺបុរសតែងតែស្ម័គ្រចិត្តចូលទៅជួយនៅពេលឃើញស្ត្រីកំពុងធ្វើការងារធ្ងន់អ្វីមួយ ពីព្រោះបុរសមានកម្លាំងខ្លាំងជាងស្ត្រី។ ជនជាតិខ្មែរតែងតែចងចាំនិងឲ្យតម្លៃការជួយគ្នាទៅវិញទៅមកបានយូរអង្វែងណាស់។

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ការជូនជាម្ហូបឬចំណីចំណុកបន្តិចបន្តួចជាញឹកញាប់ទៅអ្នកជិតខាងឬអ្នកធ្លាប់មានគុណ ទោះជាមិនមែនក្នុងឱកាសអ្វីជាពិសេសដ៏ដោយ គឺជាទម្លាប់របស់ជនជាតិខ្មែរដើម្បីសម្តែងការអរគុណ។

| | |
|---|---|
| ស្ម័គ្រចិត្ត | to be willing to |
| ការងារធ្ងន់ | heavy work |
| មានកម្លាំងខ្លាំងជាង | to be stronger than |
| ចងចាំ | to remember |
| ឲ្យតម្លៃ | to value sth. |
| ជួយគ្នាទៅវិញទៅមក | to help each other |
| យូរអង្វែង | for a long time |
| ចំណីចំណុក | snacks |
| អ្នកជិតខាង | neighbor |
| អ្នកធ្លាប់មានគុណ | someone who has helped, someone who has been good/kind |
| ក្នុងឱកាស | at the occasion of |
| ជាពិសេស | specially |
| ទម្លាប់ | habit, custom |
| សម្តែងការអរគុណ | to express gratitude |

## Additional dialogue

វិបុល៖ មានត្រូវការឲ្យជួយអីទៀតអត់?
កញ្ញា៖ ចាស។ ខ្ញុំចង់ឲ្យវិបុលជួយរើទូរទស្សន៍នោះមកដាក់ខាងនេះវិញ។
វិបុល៖ អូខេ។ មានអីទៀតអត់?
កញ្ញា៖ អស់ហើយ វិបុល។ អរគុណច្រើន។ ក្រៅពីហ្នឹងខ្ញុំធ្វើខ្លួនឯងបាន។

| | |
|---|---|
| រើ | to move |
| ទូរទស្សន៍ | TV |
| អស់ហើយ | nothing more / we’re done |
| ក្រៅពីហ្នឹង | the rest |
| ខ្ញុំធ្វើខ្លួនឯងបាន | I can do it by myself |

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.